ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# "សប្តាហ៍គាំពារសង្គម ២០២៣"

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣

នាព្រឹកថ្ងៃចន្ទ ៨រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើក "សប្តាហ៍គាំពារសង្គម" ឆ្នាំ២០២៣ ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ។ កម្មវិធីនេះរៀបចំឡើងដោយក្រុមប្រឹក្សាជាតិគាំពារសង្គម និងដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត ដែលជាផ្នែកមួយនៃការពង្រឹងយន្តការអភិបាលកិច្ចល្អក្នុងប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ដោយអនុលោមតាមការចង្អុលបង្ហាញរបស់ **"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥"** និង **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** របស់រាជរដ្ឋាភិបាល។

"**សប្តាហ៍គាំពារសង្គម**" ជាព្រឹត្តិការណ៍ប្រចាំឆ្នាំដែល **ក្រុមប្រឹក្សាជាតិគាំពារសង្គម** បានសម្រេចបង្កើត និងប្រារព្ធចាប់តាំងពីឆ្នាំ២០២២មក ក្នុងគោលបំណងបង្កើតជាវេទិកាពិភាក្សាអំពីទិដ្ឋភាពគោលនយោបាយគាំពារសង្គម និងលើទិដ្ឋភាពបច្ចេកទេសនៃដំណើរការគ្រប់គ្រង និងចាត់ចែងអន្តរាគមន៍គាំពារសង្គមនានា រវាងស្ថាប័នរបស់រាជរដ្ឋាភិបាលជាមួយភាគីពាក់ព័ន្ធនានា រួមមានដៃគូអភិវឌ្ឍន៍, តំណាងនិយោជក, តំណាងនិយោជិត, អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត។ បន្ថែមលើនេះ "**សប្តាហ៍គាំពារសង្គម**" ក៏ត្រូវបានប្រើជាយន្តការមួយដែលអាចលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីប្រព័ន្ធគាំពារសង្គម ផងដែរ។

"**សប្តាហ៍គាំពារសង្គម**" ឆ្នាំ២០២៣ នឹងផ្តោតការពិភាក្សាលើការពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈមូលបទ "**អភិបាលកិច្ចល្អ និងភាពជឿជាក់របស់សាធារណជន**" និងត្រូវបានរៀបចំក្នុងទម្រង់ជាវេទិកាមួយដែលរួមមានការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាដែលសម្របសម្រួលដោយវាគ្មិនជាថ្នាក់ដឹកនាំជាន់ខ្ពស់ អ្នកជំនាញ និងតំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀតក្នុងប្រព័ន្ធគាំពារសង្គមនៅកម្ពុជា និងដោយការចូលរួមពីសំណាក់ថ្នាក់ដឹកនាំមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធដែលមានសមាសភាពក្នុងក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ប្រមាណ ១ ០០០ នាក់ ទាំងដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូ (Zoom) ដោយមិនគិតបញ្ចូលអ្នកទស្សនាការផ្សាយបន្តផ្ទាល់ តាមរយៈបណ្តាញសង្គមនានា។ វេទិកានេះនឹងដំណើរការរយៈពេល ៣ថ្ងៃពេញ ចាប់ពីថ្ងៃទី១៣-១៥ ខែកុម្ភៈ ឆ្នាំ២០២៣ និង

បន្ទាប់ពីរយៈពេល ៣ថ្ងៃនេះ, ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងបណ្តាភាគីពាក់ព័ន្ធដទៃទៀត ត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យបន្តរៀបចំកម្មវិធីពាក់ព័ន្ធនឹងកិច្ចគាំពារសង្គម នៅតាមទីតាំងជាក់ស្តែង និងតាមលទ្ធភាពរៀងៗខ្លួន រហូតដល់ពេញ១សប្តាហ៍។

មានប្រសាសន៍ដ៏ខ្លង់ខ្លាស់ក្នុងពិធីបើកនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ការផ្តោតកិច្ចពិភាក្សាលើ "**ការពង្រឹងប្រសិទ្ធភាព និងតម្លាភាពប្រព័ន្ធគាំពារសង្គមកម្ពុជា**" ដែលបង្ហាញយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំង លើការកសាងប្រព័ន្ធគាំពារសង្គមមួយដែលប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជន។ គោលការណ៍នៃការពង្រឹងប្រសិទ្ធភាព និងតម្លាភាពពិតជាមានសារៈសំខាន់ ក្នុងការធានាថា ទាំងថវិការដ្ឋ និងថវិកាភាគទានដែលបានបង់ដោយនិយោជក និងកម្មករនិយោជិតត្រូវបានប្រើប្រាស់ចំគោលដៅ និងមិនខ្ជះខ្ជាយ ជាពិសេសក្នុងខណៈដែលការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមបាន និងកំពុងបោះជំហានទៅមុខកាន់តែប្រសើរនោះ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍បន្តទៀតថា ក្រោមការដឹកនាំដ៏ឈ្លាសវៃ, ប៉ិនប្រសប់, ម៉ឺងម៉ាត់ និងប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** ប្រទេសកម្ពុជាមានសមត្ថភាពគ្រប់គ្រងសភាពការណ៍ទល់នឹងវិបត្តិនានាបានយ៉ាងល្អប្រសើរ និងបានកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកនៅកម្រិតដែលអាចគ្រប់គ្រងបាន តាមរយៈការដាក់ចេញនូវវិធានការអន្តរាគមន៍ចាំបាច់ទាំងក្នុងផ្នែកបច្ចេកទេស និងផ្នែកសង្គម-សេដ្ឋកិច្ចជាបន្តបន្ទាប់។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យក៏បានគូសបញ្ជាក់បន្ថែមថា វឌ្ឍនភាពដែលយើងសម្រេចបានទាំងនេះ កើតឡើងដោយការខិតខំរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាមួយនឹងជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ ក៏ដូចជាការរួមចំណែករបស់គ្រប់ភាគីពាក់ព័ន្ធ ក្រោមការចង្អុលបង្ហាញដោយផ្ទាល់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលសម្តេចតែងតែចាត់ទុកការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ជាគោលនយោបាយអាទិភាពមួយរបស់រាជរដ្ឋាភិបាល នាពេលកន្លងមក និងសម្រាប់ពេលអនាគត។

សូមជម្រាបជូនថា ប្រព័ន្ធគាំពារសង្គមដែលមានសសរស្តម្ភ២ គឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គមរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងសង្គមមួយប្រកបដោយភាពសុខដុម និងជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ និងអភិវឌ្ឍប្រទេសឱ្យមានភាពធន់រឹងមាំ, និរន្តរភាព, សមធម៌, បរិយាបន្ន និងជួយឱ្យសង្គមជាតិអាចឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម មិនត្រឹមតែត្រូវការជាចាំបាច់នូវកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធប៉ុណ្ណោះទេ ថែមទាំងត្រូវការជាចាំបាច់ផងដែរ នូវការកសាងយន្តការអភិបាលកិច្ចមួយដែលមានភាពរឹងមាំ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍តម្លាភាព និងគណនេយ្យភាព ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព និងនិរន្តរភាព។

សូមជម្រាបជូនថា ក្រោយពីការបង្កើតឡើងនៅឆ្នាំ២០១៧, "**ក្រុមប្រឹក្សាជាតិគាំពារសង្គម**" បំពេញតួនាទីជាសេនាធិការតែមួយរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្របសម្រួលលើការរៀបចំគោលនយោបាយ, ការកែទម្រង់ស្ថាប័នពាក់ព័ន្ធក៏ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដូចជា÷ (១) ការរៀបចំរចនាសម្ព័ន្ធថ្មីរបស់ **បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.),** (២) ការបង្កើត និងដាក់ឱ្យដំណើរការ **មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.)** និង (៣) ការខិតខំកែទម្រង់ **ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល** ឱ្យក្លាយជាស្ថាប័នបញ្ជាក់ចំណាយសម្រាប់ប្រព័ន្ធថែទាំសុខភាពសង្គមទាំងមូល។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បានបង្កើត និងដាក់ឱ្យដំណើរការ "**និយ័តករសន្តិសុខសង្គម**" ដែលជាសេនាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធ្វើនិយ័តកម្ម និងត្រួតពិនិត្យលើប្រតិបត្តិការក្នុងប្រព័ន្ធសន្តិសុខសង្គមផងដែរ ដើម្បីធានាថា ដំណើរការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមនានា ត្រូវបានអនុវត្តប្រកបដោយភាពត្រឹមត្រូវ តម្លាភាព និងគណនេយ្យភាពចំពោះសាធារណជន ជាពិសេស ចំពោះនិយោជក និងកម្មករ

និយោជិត ដែលមានកាតព្វកិច្ចបង់ភាគទានចូលទៅក្នុងមូលនិធិរួមគ្នាមួយ។ ថ្មីៗនេះរាជរដ្ឋាភិបាលក៏បាន អនុម័ត និងដាក់ឱ្យអនុវត្តនូវ “**អនុក្រឹត្យស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម**” ដើម្បីផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការចាប់ផ្តើម បំពេញការងាររបស់និយ័តករសន្តិសុខសង្គម ដើម្បីពង្រឹងប្រព័ន្ធគាំពារសង្គមទាំងមូលឱ្យកាន់តែប្រសើរ។

ដោយឡែកសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារ ក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ទោះបីបច្ចុប្បន្នឥទ្ធិពលជំងឺកូវីដ-១៩ បានថមថយក៏ដោយ ក៏រាជរដ្ឋាភិបាលសម្រេចបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់នេះ ក្នុងឆ្នាំ២០២៣ទៀត ដើម្បីបន្តជួយគាំទ្រគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងដំណាក់កាលនៃការស្តារជីវភាពឡើងវិញ។ កម្មវិធីនេះបានអនុវត្តអស់រយៈពេល **៣១ខែ** មកហើយ និងបានផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ចំនួនប្រមាណ ៧០ ម៉ឺនគ្រួសារ ដែលមានសមាជិកចំនួនប្រមាណ ២,៧លាននាក់ នៅទូទាំងប្រទេស និងបានប្រើប្រាស់ថវិកាជាតិសុទ្ធសាធ សរុបចំនួនប្រមាណ **៩៣២ លានដុល្លារអាមេរិក**។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានឆ្លៀតផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ប្រគល់បណ្ណសរសើរជូនតំណាងក្រសួង-ស្ថាប័ន ដែលបានចូលរួមក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា និងសហការក្នុងការដឹកនាំ និងអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមដោយជោគជ័យ និងបណ្ណទទួលស្គាល់ដែលបង្ហាញពីការវាយតម្លៃខ្ពស់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ជូនដៃគូអភិវឌ្ឍន៍សំខាន់ក្នុងប្រព័ន្ធគាំពារសង្គម ព្រមទាំងប្រគល់បណ្ណសរសើរជូនសប្បុរសជនដែលជាសមាជិកស្ថាបនិករបស់មូលនិធិគន្ធបុប្ផាកម្ពុជាដែលបានចូលរួមបរិច្ចាគដ៏សំខាន់ និងជាបន្តបន្ទាប់ដើម្បីជាការលើកទឹកចិត្តឱ្យបន្តបរិច្ចាគ និងដើម្បីរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងការបន្តបេសកកម្មលើកកម្ពស់សុខុមាលភាពមាតា និងទារក ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានគូសរំលេចថា ការបន្តផ្តល់សេវាពិនិត្យ និងព្យាបាលទារក និងកុមារនៅមន្ទីរពេទ្យគន្ធបុប្ផា ប្រកបដោយគុណភាព និងដោយមិនគិតថ្លៃ ក៏ជាផ្នែកមួយនៃការផ្តល់កិច្ចគាំពារសង្គមផងដែរ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានឆ្លៀតយកឱកាសនេះ សម្តែងនូវការកោតសរសើរ និងថ្លែងអំណរគុណ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, អ្នកនាងកញ្ញា** ចំពោះការចូលរួមបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា ក្នុងការរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យនេះ។